**សេចក្ដីប្រកាសព័ត៌មាន**

ថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០១៥

**ទីក្រុងសម្រាប់កុមារ**

អបអរទិវាកុមារអន្តរជាតិលើកទី៦៦ នៅក្នុងតំបន់ដែលមានប្រជាពលរដ្ឋក្រីក្រក្នុងរាជធានីភ្នំពេញ

**ទិវាកុមារអន្តរជាតិឆ្នាំ២០១៥៖ ប្រារព្ធឡើងនៅសហគមន៍ប្រាំងចំរេះ។**

អង្គការសមាគមជាងត្នោតជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក រួមសហការជាមួយទីភ្នាក់ងារអភិវឌ្ឍន៍នៃសាធារណៈរដ្ឋឆែក ដែលមានអង្គការភីពភលអ៊ីននីត (ភីន)កំពុងប្រារព្ធព្រឹត្តិការណ៍ "**ទីក្រុងសម្រាប់កុមារ**" ដែលជាឱកាសមួយដើម្បីប្រារព្ធទិវាកុមារអន្តរជាតិលើកទី៦៦ នៅក្នុងភូមិក្រីក្រចំនួន៤នៅក្នុងរាជធានីភ្នំពេញ។

**ព្រឹត្តិការណ៍នេះនឹងត្រូវប្រារព្ធនៅខាងមុខព្រះ វិហារធំឥស្លាមគីឡូលេខ០៩ ក្នុងភូមិ៣ សង្កាត់ប្រាំងចំរេះទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ថ្ងៃទី០១ មិថុនា ឆ្នាំ២០១៥ ចាប់ពីម៉ោង ០៨:០០ ដល់ម៉ោង ១១:០០ ព្រឹក។**

ស្ថានភាពសម្រាប់កុមារដែលកំពុងរស់នៅក្នុងលំនៅឋានក្រីក្រក្នុងទីក្រុង (ដែលក្នុងនោះមាន៣៤០ទីតាំងដោយយោងទៅតាម របាយការណ៍អង្កេតនៅក្នុងរាជធានីភ្នំពេញដែលស្រាវជ្រាវដោយ អង្គការសមាគមជាងត្នោតនៅក្នុងឆ្នាំ២០១៤) បាននិងកំពុងរងផលប៉ះពាល់ដោយសាការទទួលបានការផ្ដល់សេវា សាធារណៈមានកំរិតទាប រួមទាំងការផ្គត់ផ្គង់ទឹកអនាម័យ ប្រព័ន្ធលូ និងភ្លើងអគ្គីសនី។ យោងតាមការស្រាវជ្រាវ បោះពុម្ពផ្សាយដោយអង្គការភីពភលអ៊ីននីត (ភីន) និងអង្គការយូនីសេហ្វ នៅដើម ឆ្នាំនេះបានឲ្យ ដឹងថា៖ រាល់កុមារម្នាក់ក្នុងចំណោមបីនាក់នៅក្នុងសហគមន៍ក្រីក្រនៅតាមទីក្រុងគឺមានសភាពស្គមស្គាំង។ កុមារទាំងនេះ គឺមានមាឌតូចជាងធម្មតា ខ្សោយកម្លាំង និងរៀនមិនសូវពូកែ ដូចកុមារដែលមានលទ្ធភាពទទួលចំណីអាហារគ្រប់គ្រាន់ ការផ្គត់ផ្គង់ទឹកស្អាត និងមានអនាម័យ។

នៅក្នុងឆ្នាំ២០១៤ អង្គការសមាគមជាងត្នោត និងអង្គការភីពភលអ៊ីននីត បានចាប់ផ្ដើមគម្រោងសហប្រតិបត្តការដែលមានឈ្មោះថា គម្រោងរៀបចំដីធ្លីនិងសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជាក្រោមពាក្យស្លោក"**ទីក្រុងសម្រាប់យើងទាំងអស់គ្នា**"។ ដែល ផ្ដល់ហិរញ្ញវត្ថុដោយសហភាពអឺរ៉ុបនិងទីភ្នាក់ងារអភិវឌ្ឍន៍នៃសាធារណៈរដ្ឋឆែក ក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងដើម្បីផ្សព្វផ្សាយអំពីសិទ្ធិជាមូល ដ្ឋានជុំវិញ ការអភិវឌ្ឍន៍នៅក្នុងទីក្រុង។ គម្រោងសហប្រតិបត្តការនេះត្រូវធ្វើនៅក្នុងភូមិចំនួនបួននៅក្នុង សង្កាត់ ប្រាំងចំរេះ១និង២ ដែលមានទីតាំងនៅស្របនឹងមាត់ទន្លេសាបដែលជាទីកន្លែងដែលមិនមានសុវត្ថិភាពដីធ្លី ឬហៅថា សហគមន៍ដែលកំពុង ប្រឈមមុខនឹងការបណ្ដេញចេញ។ គម្រោងសហប្រតិបត្តិការនេះធ្វើជាមួយសហគមន៍ និង អាជ្ញាធរដែនដីដើម្បីផ្ដល់ជូន ប្រជាពលរដ្ឋនូវការវាយតម្លៃអំពីអំណះអំណាងនៃការ កាន់កាប់ដីធ្លីដោយស្របច្បាប់ និងដើម្បីបង្កើតនូវផែនការសម្រាប់ អភិវឌ្ឍន៍ទីក្រុងថ្មីនៅនឹងកន្លែងដើម្បីធ្វើឲ្យ ការប្រើប្រាស់ដីធ្លីកាន់តែមានប្រសិទ្ធិភាព ជៀសវាងការតាំងលំនៅថ្មីដោយមិនពេញចិត្ត។

ក្នុងចំណោមសកម្មភាពនៃការពង្រឹងសហគមន៍នៃគម្រោងនេះមានដូចជា ការប្រមូលទិន្នន័យ ការធ្វើផែនទី និងសិក្ខាសាលា។ អង្គការសមាគមជាងត្នោត និងអង្គការភីពភលអ៊ីននីតកំពុងរៀបចំប្រារព្ធព្រឹត្តិការណ៍ដែលមានរយៈពេល កន្លះថ្ងៃសម្រាប់ កុមារចំនួន១០០នាក់ និងមាតាបិតារបស់គេមកពីភូមិចំនួន០៤ (ភូមិ១ ភូមិ២ ភូមិ៣ និងភូមិយ) ដែលការប្រារព្ធនេះនឹង ត្រូវធ្វើនៅខាងមុខព្រះវិហារធំឥស្លាមគីឡូលេខ០៩ ក្នុងភូមិ៣ សង្កាត់ប្រាំងចំរេះទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។ព្រឹត្តិការណ៍នេះនឹងលើកទឹកចិត្តដល់កុមារដើម្បីឲ្យពួកគេបានគិតអំពីបរិស្ថានរស់នៅតាមទីក្រុងរបស់ពួក

គេដោយផ្តល់ឱ្យពួកគេនូវឱកាសដើម្បីពិភាក្សា និងគូរនូវអ្វីដែលទីក្រុងដ៏ល្អរបស់ពួកគេនឹងមើលទៅដូចអ្វីដែលពួកគេស្រមៃចង់ឃើញ។

លោក អ៊ី សារ៉ុម នាយកប្រតិបត្តិអង្គការសមាគមជាងត្នោតបាននិយាយថា “តាមបទពិសោធន៍របស់យើង ការអញ្ជើញកុមារនិងមាតាបិតារបស់ពួកគេឱ្យចូលរួមព្រឹត្តិការណ៍ផ្តោតលើចក្ខុវិស័យរបស់កុមារចំពោះការអភិវឌ្ឍន៍លំនៅដ្ឋាននិងទីក្រុងដ៏ល្អរបស់ពួកគេគឺជាសកម្មភាពមួយដែលបានជួយយ៉ាងច្រើនក្នុងការជម្រុញឱ្យមានការចូលរួមរបស់សហគមន៍ទាំងមូលនៅក្នុងគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងផែនទីដោយមានការចូលរួមឱ្យប្រសើរ។ លោក សារ៉ុម បានបន្ថែមថា៖ “ក្នុងរយៈពេល ១០ឆ្នាំធ្វើការនៅក្នុងសហគមន៍អ្នកក្រីក្រក្នុងទីក្រុងសមាគមជាងត្នោតបានឃើញផ្ទាល់ភ្នែកម្តងហើយម្តងទៀតអំពីរបៀបដែលកុមារត្រូវបានរងផលប៉ះពាល់ដោយស្ថានភាពរស់នៅក្រីក្រដែលមានជាញឹកញាប់កាន់តែអាក្រក់នៅក្នុងករណីនៃការតាំងលំនៅថ្មីដោយបង្ខំ។ យើងសង្ឃឹមថាព្រឹត្តិការណ៍នេះអាចជួយបង្កើនការយល់ដឹងអំពីសារៈសំខាន់នៃលំនៅដ្ឋាន កុមាររបស់យើងនៅក្នុង ទីក្រុងនេះ"។

បន្ថែមទៅលើការងារដែលអនុវត្តនៅច្រាំងចំរេះ១របស់គម្រោងរៀបចំដីធ្លីនិងសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា ក្រោមពាក្យស្លោក “**ទីក្រុងសម្រាប់យើងទាំងអស់គ្នា**” គឺគម្រោងបានរួមបញ្ចូលនិស្សិតក្នុងរាជធានីភ្នំពេញមកពីមហាវិទ្យាល័យ គ្រប់គ្រងដែនដី និងនគរ រូបនីយកម្មឱ្យចូលរួម “វគ្គសិក្សាអំពីការរៀបចំផែនការដីធ្លី”។ វគ្គសិក្សានេះពាក់ព័ន្ធ នឹងសិក្ខាសាលានិងការបង្រៀនដូចជាការ ធ្វើផែនការប្រើប្រាស់ដីដើម្បីគ្រប់គ្រងគ្រោះមហន្តរាយ, ការធ្វើផែនការកែលម្អ ហេដ្ឋារចនាសម្ព័ន្ធដីធ្លី និងសិទ្ធិមនុស្ស ។ល។ ដើម្បីជួយអ្នកធ្វើផែនការនៅតាមទីក្រុង នាពេលអនាគតឲ្យពិចារណាអំពីសារៈសំខាន់នៃសិទ្ធិជាមូលដ្ឋានទៅនឹងការអភិវឌ្ឍន៍ នៃរាជធានីរបស់ប្រទេសកម្ពុជា។

អង្គការភីពភលអ៊ីននីតបានវាយតម្លៃផងដែរដើម្បីកំណត់អំពីតំបន់ងាយរងគ្រោះមហន្តរាយបំផុតនិងសមត្ថភាពនៃធនធានមនុស្សក្នុងតំបន់ដើម្បីទប់ទល់នឹងគ្រោះមហន្តរាយនិងស្នើសុំវិធានការបន្ធូរបន្ថយសមស្រប។

**សម្រាប់ព័ត៌មានបន្ថែមសូមមេត្តាទាក់ទង៖**

លោក អ៊ី សារ៉ុម នាយកប្រតិបត្តិអង្គការសមាគមជាងត្នោតតាមរយៈទូរស័ព្ទលេខ 012 836 533
លោក SASIN Piotr, នាយកប្រចាំប្រទេស អង្គការភីពភលអ៊ីននីត 011 676 331